Multicultural HIV/AIDS and Hepatitis C Service

A statewide service auspiced by SYDNEY SOUTH WEST AREA HEALTH SERVICE NSW HEALTH

NSW HEALTH

*NSW Health Factsheet - Khmer*

# ទំនាក់ទំនងរវាងរោគ TB និងរោគ HIV

***The connection between TB and HIV***

នេះគឺជាសន្លឹកពត៌មានអំពីរោគរបេង (TB) និងមេរោគកង្វះភាពស៊ាំនឹងជម្ងឺក្នុងខ្លួនប្រាណមនុស្ស (HIV) ជាមេរោគបណ្តាលឲ្យកើតសហានិមិត្តហេតុនៃការមានរោគកង្វះភាពស៊ាំនឹងជម្ងឺ (អេដស៍) (AIDS)។ មនុស្សដែលមានរោគ HIV ទំនងជាឈឺដោយសារការឆ្លងរោគ និងជម្ងឺដទៃទៀត។ TB គឺជាជម្ងឺមួយ ក្នុងចំណោមជម្ងឺទាំងនេះ។ ប្រសិនបើលោកអ្នកបានធ្វើរោគវិនិច្ឆ័យឃើញថាមានរោគ TB ឬប្រសិនបើលោកអ្នកមានរោគ HIV សន្លឹកពត៌មាននេះគឺសំរាប់លោកអ្នក។

ក្នុងចំណោមមនុស្សដែលគេប៉ាន់ប្រមាណចំនួន៤០លាននាក់ ដែលរស់នៅមានរោគ HIV ឬ AIDS ប្រមាណជា១៣លាននាក់ក៏មានរោគ TB ដែរ។ ប្រសិនបើលោកអ្នកមានរោគ HIV ក៏ដូចជារោគ TB ដែរនោះ ការរកឃើញរោគទាន់ពេលគឺជាការសំខាន់ដើម្បីឲ្យលោកអ្នកចាប់ផ្តើមធ្វើការព្យាបាលទាំងរោគ HIV និងទាំងរោគ TB។ ប្រសិនបើពុំបានព្យាបាលរោគឆ្លងទាំងពីរទេនេះ វាអាចធ្វើការជាមួយគ្នា ហើយបណ្តាលឲ្យកើតទៅជាជម្ងឺយ៉ាងធ្ងន់ធ្ងរ។

## ផ្នែកទី១: រោគរបេង (TB)

### តើរោគ TB ជាអ្វី?

រោគ TB បណ្តាលមកពីបាក់តេរី (មេរោគ)។ ជាទូទៅ វាជាជម្ងឺដែលប៉ះពាល់ដល់សួត ក៏ប៉ុន្តែវាអាចប៉ះពាល់ដល់គ្រឿងដទៃទៀតក្នុងខ្លួនប្រាណផងដែរដូចជាខួរក្បាល តម្រងនោម ឬឆ្អឹងខ្នង។ រោគ TB អាចមានសកម្មភាពនៅក្នុងខ្លួនប្រាណ ឬមិនទាន់ចេញមុខ (ដេកលក់)។ ប្រសិនបើពុំបានព្យាបាលទេ រោគ TB សកម្ម អាចបណ្តាលឲ្យកើតមានបញ្ហាសុខភាពយ៉ាងធ្ងន់ធ្ងរ ឬដល់ស្លាប់។

### តើរោគ TB ឆ្លងរាលដាលយ៉ាងដូចម្តេច?

បាក់តេរីនៃរោគ TB (មេរោគ) ឆ្លងរាលដាលពីមនុស្សម្នាក់ ទៅមនុស្សម្នាក់តាមខ្យល់អាកាស ហើយតាមធម្មតាឆ្លងរាលដាលនៅពេលដែលមនុស្សមាន TB សកម្ម ក្អក សើច កណ្តាស់ ឬច្រៀង។ នរណាម្នាក់ដែលនៅជិត អាចដកដង្ហើមស្រូបយកបាក់តេរី TB ទាំងនេះ ហើយឆ្លងរោគ TB។ រោគ TB មិនអាចឆ្លងរាលដាលដោយសារការប្រើប្រាស់ប្រដាប់ប្រដាក្នុងផ្ទះរួមគ្នាឡើយ ដូចជាកែវ ឬចាន ឬដោយសារទឹកមាត់នៅពេលថើបជញ្ជក់មាត់នរណាម្នាក់។

### តើអ្វីទៅជារោគសញ្ញានៃរោគ TB សកម្ម?

អ្នកដែលមានរោគ TB សកម្ម ជាញឹកញាប់:

| | |
|---|---|
| • ទទួលអារម្មណ៍ខ្សោយ ឬឈឺ<br>• ស្រកទម្ងន់យ៉ាងលឿន<br>• ក្អក (ជួនកាលមានឈាម) និងឈឺដើមទ្រូង | • គ្រុនក្តៅ ហើយ<br>• បែកញើសនៅពេលយប់<br>• ឬជួនកាលពុំមានរោគសញ្ញាអ្វីឡើយ |

### តើរោគ TB សកម្ម និងរោគ TB មិនទាន់ចេញ មុខមានភាពខុសគ្នាអ្វីខ្លះ?

មនុស្សដែលមានរោគ TB សកម្ម ឈឺបណ្តាលមកពីចំនួនមេរោគ TB ដ៏ច្រើនមានសកម្មភាពនៅក្នុងខ្លួនរបស់គេ។ មនុស្សដែលមានរោគ TB មិនទាន់ចេញមុខ ក៏មានបាក់តេរីដែលបណ្តាលឲ្យកើតរោគ TB សកម្ម ផងដែរ ក៏ប៉ុន្តែគេមិនបានឈឺទេដោយសារបាក់តេរីមិនទាន់ចេញមុខ (ដេកលក់) នៅក្នុងខ្លួនរបស់គេ។ តាមធម្មតា គេធ្លាប់បានរងការប៉ះពាល់ដោយបាក់តេរី TB ពីអតីតកាលមកហើយ។ ទោះបីជាយ៉ាងណាក្តី មនុស្សដែលមានរោគ TB មិនទាន់ចេញមុខ ក៏អាចបង្កើតជារោគ TB សកម្ម នៅក្នុងពេលអនាគតដែរជាពិសេសប្រសិនបើគេមានរោគ HIV។

ប្រសិនបើលោកអ្នកមានរោគ **TB សកម្ម** មានន័យថាលោកអ្នកៈ
- មានបាក់តេរី TB សកម្មនៅក្នុងខ្លួនលោកអ្នក
- ឈឺ ហើយលោកអ្នកអាចមានរោគសញ្ញាទាំងឡាយដូចជា ក្អក គ្រុន ស្រកទម្ងន់ ការនឿយហត់ និងការបែកញើសនៅពេលយប់
- ប្រហែលអាចចម្លងបាក់តេរីរោគ TB ទៅមនុស្សឯទៀត
- អាចប្រើថ្នាំព្យាបាលដើម្បីព្យាបាលជម្ងឺឲ្យជា

ប្រសិនបើលោកអ្នកមានរោគ **TB មិនទាន់ចេញមុខ** បានន័យថាលោកអ្នកៈ
- មានបាក់តេរីរោគ TB ក៏ប៉ុន្តែវាមិនទាន់សកម្ម
- ពុំទាន់ឈឺទេ
- ពុំអាចចម្លងបាក់តេរី TB ទៅមនុស្សដទៃទៀតបានទេ
- អាចប្រើថ្នាំព្យាបាលដើម្បីការពារកុំឲ្យកើតរោគ TB សកម្មក្នុងពេលអនាគត។

# ផ្នែកទី២: មេរោគកង្វះភាពស៊ាំនឹងជម្ងឺក្នុងខ្លួនប្រាណមនុស្ស (HIV)

## តើរោគ HIV ជាអ្វី?

រោគ HIV គឺជាមេរោគដែលអាចបណ្តាលឲ្យកើតជម្ងឺ AIDS។ រោគ HIV វាយប្រហារទៅលើប្រព័ន្ធការពាររោគក្នុងរាងកាយមនុស្ស។ ប្រសិនបើលោកអ្នកត្រូវបានឆ្លងដោយរោគ HIV លោកអ្នកត្រូវបានគេហៅថាមានរោគ HIV វិជ្ជមាន។ នេះបានន័យថារោគ HIV បានចូលទៅក្នុងចរន្តឈាមរបស់លោកអ្នកហើយ។

## តើរោគ HIV ឆ្លងយ៉ាងដូចម្តេច?

រោគ HIV ត្រូវបានគេរកឃើញនៅក្នុងវត្ថុរាវផងខ្លួនដូចជាឈាម ទឹកកាម ទឹករំអិលយោនី និងនៅក្នុងទឹកដោះមនុស្ស។ ការឆ្លងរោគ HIV អាចកើតមានឡើងប៉ុណ្ណោះ នៅពេលដែលវត្ថុរាវក្នុងខ្លួនមួយ ឬច្រើនមុខនៅក្នុងចំណោមវត្ថុរាវទាំងនេះ មកអំពីមនុស្សដែលកើតរោគនេះ ឆ្លងចូលទៅក្នុងចរន្តឈាមរបស់មនុស្សឯទៀត។

រោគ HIV អាចឆ្លងដោយរបៀបដូចតទៅនេះតែប៉ុណ្ណោះ:
- ការរួមភេទដោយពុំប្រើស្រោមអនាម័យ (ការរួមភេទដែលគ្មានអ្វីការពារ)
- ការប្រើម្ជុលចាក់ ស៊ីរ៉ាំង និងគ្រឿងឧបករណ៍ចាក់គ្រឿងញៀនដទៃទៀតរួមគ្នា
- ចម្លងពីម្តាយ ទៅកូនក្នុងពេលមានផ្ទៃពោះ ពេលសម្រាលកូន ឬការបំបៅកូននឹងទឹកដោះ
- ការចាក់បញ្ចូលឈាម និង/ឬផលិតផលផ្តល់ឈាម (នៅប្រទេសអូស្ត្រាលី ផលិតផលឈាមត្រូវបានគេពិនិត្យរកមើលរោគ HIV តាំងពីឆ្នាំ១៩៨៥មកម្ល៉េះ)

រោគ HIV **មិនអាច**ឆ្លងដោយសារៈ ការក្អក ថើប កណ្តាស់ ខាក ស្តោះ ស្រែក យំ ការប្រើកាំបិត កម្រាលពូក ស្រោមខ្នើយ បង្គន់ បន្ទប់ទឹក ឬការប៉ះពាល់ម្តងម្កាលតាមបែបផែនណាមួយឡើយ។

## តើអ្វីទៅជារោគសញ្ញានៃរោគ HIV?

លោកអ្នកមិនអាចដឹងថាអ្នកណាម្នាក់មានរោគ HIV ដោយគ្រាន់តែក្រឡេកមើលនោះឡើយ។ មនុស្សភាគច្រើនដែលមានរោគ HIV មើលទៅហាក់បីដូចជាមានសុខភាពល្អ ហើយពុំមានរោគសញ្ញាអ្វីឡើយ។ វាប្រហែលជាត្រូវការពេលប្រហែលពីរ ឬបីឆ្នាំ មុននឹងរោគសញ្ញាណាមួយចាប់ផ្តើមបង្ហាញឲ្យឃើញ ហើយមនុស្សជាច្រើនដែលមានរោគ HIV ពុំទាំងដឹងថាខ្លួនគេមានរោគនេះឡើយ។

## តើរោគ HIV និងជម្ងឺ AIDS មានភាពខុសគ្នាអ្វីខ្លះ?

រោគ HIV វាយប្រហារទៅលើប្រព័ន្ធការពាររោគរបស់រាងកាយ។ ប្រសិនបើរោគនេះពុំបានទទួលការព្យាបាលទេ រោគ HIV ធ្វើឲ្យខូចខាតដល់ប្រព័ន្ធការពាររោគ ដើម្បីកុំឲ្យប្រព័ន្ធនេះអាចប្រយុទ្ធនឹងការឆ្លងរោគដែលគេតែងជួបប្រទះ ហើយមនុស្សអាចមានគ្រោះថ្នាក់ដោយសារការឆ្លងជម្ងឺ និងអាចរហូតដល់ស្លាប់។ នេះគឺជាជម្ងឺមួយដែលគេស្គាល់ថាជាជម្ងឺ AIDS - សហនិមិត្តហេតុនៃការមានរោគកង្វះភាពស៊ាំនឹងជម្ងឺ។

ប្រសិនបើលោកអ្នកមានរោគ HIV បានន័យថាលោកអ្នកៈ
- មានវ៉ាយរ៉ុសដែលអាចបណ្តាលឲ្យកើតជម្ងឺ AIDS
- ប្រហែលជាអាចពុំមានរោគសញ្ញាណាមួយឡើយ
- អាចព្យាបាលបាន។

## ផ្នែកទី៣: រោគ TB និងរោគ HIV - ការធ្វើតេស្ត និងការថតឆ្លុះពិនិត្យរកមើលជម្ងឺ

រោគ HIV ធ្វើឲ្យប្រព័ន្ធការពាររោគចុះអន់ខ្សោយ – “ វាបើកទ្វារឲ្យមេរោគឆ្លងដទៃទៀតចូល ” – ដូច្នេះ ប្រសិនបើលោកអ្នកមានរោគ HIV និងរោគ TB មិនទាន់ចេញមុខ លោកអ្នកទំនងជាកើតរោគ TB សកម្មជាមិនខាន។ ប្រសិនបើពុំបានព្យាបាលរោគទាំងពីរនេះទេ វាអាចធ្វើការជាមួយគ្នា ហើយបណ្ដាលឲ្យកើតទៅជាជម្ងឺយ៉ាងធ្ងន់ធ្ងរ។

### ហេតុអ្វីបានជាការសំខាន់ដែលត្រូវធ្វើតេស្តរកមើលរោគ TB ប្រសិនបើខ្ញុំមានរោគ HIV?

ប្រសិនបើលោកអ្នកមានរោគ HIV នេះគឺជាការសំខាន់ដែលត្រូវរកឲ្យបានដឹងថាតើលោកអ្នកមានរោគ TB មិនទាន់ចេញមុខដែរឬទេ ដោយព្រោះថារោគ TB មិនទាន់ចេញមុខ ទំនងជាក្លាយទៅជារោគ TB សកម្ម នៅក្នុងខ្លួនមនុស្សដែលមានរោគ HIV។ ប្រសិនបើលោកអ្នកមានរោគ TB មិនទាន់ចេញមុខ ព្រមទាំងរោគ HIV លោកអ្នកអាចទទួលការព្យាបាលបាន។

### ហេតុអ្វីបានជាការសំខាន់ដែលត្រូវធ្វើតេស្តរកមើលរោគ HIV ប្រសិនបើខ្ញុំមានរោគ TB សកម្ម?

ប្រសិនបើលោកអ្នកមានរោគ TB សកម្ម នេះគឺជាការសំខាន់ដែលត្រូវរកឲ្យបានដឹងថាតើលោកអ្នកមានរោគ HIV ដែរឬទេ ដោយព្រោះថាជួនកាលមនុស្សដែលមានរោគ TB សកម្ម គឺជាមនុស្សដែលមានរោគ HIV ផងដែរ។ នេះគឺជាការសំខាន់ដែលត្រូវធ្វើតេស្ត ដោយព្រោះថាប្រសិនបើលោកអ្នកមានរោគ HIV ព្រមទាំងរោគ TB សកម្ម ផងដែរនោះ លោកអ្នកអាចទទួលការព្យាបាលបាន។

### តើតេស្តអ្វីខ្លះដែលខ្ញុំត្រូវការ ដើម្បីរកមើលរោគ TB?

តេស្តទូទៅបីយ៉ាងដែលគេអាចធ្វើដើម្បីរកមើលរោគ TB នៅមន្ទីរពិនិត្យសួតរដ្ឋញូវសៅវែល។ តេស្តទាំងនេះគឺ:

- តេស្តជោះលើស្បែករកមើលរោគរបេង (TST) ដែលគេធ្លាប់ស្គាល់ដែរថាជាតេស្ត Mantoux
- ការធ្វើតេស្តថតមើលសួតដោយប្រើកាំរស្មីអិក្ស
- ការធ្វើតេស្តកំហាក (ខាកស្ដោះ)។

តេស្តទាំងនេះអាចរកឃើញរោគ ប្រសិនបើលោកអ្នកធ្លាប់បានរងការប៉ះពាល់ដោយរោគ TB ពីអតីតកាល (រោគ TB មិនទាន់ចេញមុខ) ឬប្រសិនបើលោកអ្នកមានរោគ TB សកម្ម។ ការសម្រេចថាតើតេស្តណាមួយដែលចាំបាច់ត្រូវធ្វើ គឺត្រូវសម្រេចដោយមន្ទីរពិនិត្យសួត។

### តើតេស្តអ្វីខ្លះដែលខ្ញុំត្រូវធ្វើដើម្បីរកមើលរោគ HIV?

តេស្តឈាមដើម្បីរកមើលរោគ HIV អាចធ្វើបាននៅមន្ទីរពិនិត្យសុខភាពផ្នែកផ្លូវភេទណាមួយ នៅរដ្ឋញូវសៅវែល ឬនៅកន្លែងវេជ្ជបណ្ឌិតរបស់លោកអ្នក។

### តើអស់ថ្លៃប៉ុន្មាន?

គ្រប់តេស្តសំរាប់រោគ TB ទាំងអស់ ដែលធ្វើនៅមន្ទីរពិនិត្យសួតរដ្ឋញូវសៅវែល **ឥតគិតថ្លៃទេ**។ លោកអ្នកប្រហែលជាត្រូវធ្វើការណាត់ជួបដើម្បីទៅមន្ទីរពិនិត្យសួត ក៏ប៉ុន្តែលោកអ្នកពុំចាំបាច់ត្រូវការមានប័ណ្ណមេឌីឃែរឡើយ។

ការធ្វើតេស្ត HIV នៅមន្ទីរពិនិត្យសុខភាពផ្នែកផ្លូវភេទ នៅរដ្ឋញូវសៅវែល **ឥតគិតថ្លៃទេ** ហើយលោកអ្នកពុំចាំបាច់ត្រូវការមានប័ណ្ណមេឌីឃែរឡើយ។ ការធ្វើតេស្តនេះក៏មាននៅកន្លែងវេជ្ជបណ្ឌិតប្រចាំតំបន់របស់លោកអ្នកដែរ ក៏ប៉ុន្តែលោកអ្នកចាំបាច់ត្រូវការមានប័ណ្ណមេឌីឃែរ។

## ផ្នែកទី៤: រោគ TB និង HIV - ការព្យាបាល

### ការព្យាបាលរោគ TB

រោគ TB សកម្មអាចព្យាបាល និងមើលឲ្យជាបានចំពោះមនុស្សដែលមានរោគ HIV។ រោគ TB សកម្ម ត្រូវគេព្យាបាលដោយប្រើការរួមផ្សំនៃថ្នាំផ្សះសំរាប់រយៈពេលយ៉ាងតិច៦ខែ។ គិលានុបដ្ឋាកតាមមើលលោកអ្នកនៅពេលប្រើថ្នាំព្យាបាលរោគ TB ដើម្បីឆែកមើលឥទ្ធិពលប៉ះពាល់ណាមួយ និងធ្វើឲ្យប្រាកដថាការព្យាបាលត្រូវបានបំពេញ។

រោគ TB មិនទាន់ចេញមុខ ដែលមាននៅក្នុងខ្លួនមនុស្សមានរោគ HIV ដែរនោះ ត្រូវបានព្យាបាលដោយថ្នាំផ្សះសំរាប់រយៈពេល ៦ខែដើម្បីការពារការរីកដុះដាលនៃរោគ TB សកម្ម។

### ការព្យាបាលរោគ HIV

ក្នុងពេលបច្ចុប្បន្ននេះ ពុំមានថ្នាំសំរាប់ព្យាបាលរោគ HIV និងជម្ងឺ AIDS ឲ្យជាឡើយ។ ទោះជាយ៉ាងណាក្តី ថ្នាំព្យាបាលជាច្រើនត្រូវបានបង្កើតឡើងដើម្បីប្រឆាំងនឹងរោគ HIV ហើយកាត់បន្ថយល្បឿននៃការខូចខាតប្រព័ន្ធការពាររោគដែលបណ្តាលដោយសាររោគ HIV។ ដោយសារការព្យាបាល មនុស្សជាច្រើនដែលមានរោគ HIV អាចស្រួលខ្លួន និងបន្តរស់នៅដោយសុខភាពល្អ ជីវិតមានការមមាញឹក ហើយបានបំពេញតាមបំណង។

### តើអស់ថ្លៃប៉ុន្មាន?

គ្រប់ទាំងការព្យាបាលរោគ TB **ឥតគិតថ្លៃទេ**។ ពុំចាំបាច់ត្រូវការមានប័ណ្ណមេឌីឃែរឡើយ។

ការព្យាបាលរោគ HIV គឺមានសំរាប់មនុស្សគ្រប់រូបដែលមានប័ណ្ណមេឌីឃែរ ដោយបង់ថ្លៃបន្តិចបន្តួចប៉ុណ្ណោះ។

## ផ្នែកទី៥: ពត៌មានឯទៀត

### តើការមានរោគ HIV ឬរោគ TB នឹងធ្វើឲ្យប៉ះពាល់ដល់ស្ថានការណ៍អន្តោប្រវេសន៍របស់ខ្ញុំដែរឬទេ?

### រោគ TB:

ការមានរោគ TB មិនទាន់ចេញមុខ ឬរោគ TB សកម្ម នឹងពុំមានប៉ះពាល់ដល់ស្ថានការណ៍អន្តោប្រវេសន៍របស់លោកអ្នកនៅក្នុងប្រទេសអូស្ត្រាលីឡើយ។

### រោគ HIV:

ប្រសិនបើលោកអ្នកជាពលរដ្ឋរស់នៅជាអចិន្ត្រៃយ៍ ការមានរោគ HIV នឹងពុំប៉ះពាល់ដល់ស្ថានការណ៍អន្តោប្រវេសន៍របស់លោកអ្នកទេ។ ទោះជាយ៉ាងណាក្តី អ្នកសុំរស់នៅជាអចិន្ត្រៃយ៍ បានតម្រូវឲ្យបំពេញតម្រូវការផ្នែកសុខភាពដែលរាប់បញ្ចូលទាំងការធ្វើតេស្តរោគ HIV និងការថតមើលសួតដោយប្រើកាំរស្មីអិក្ស។ ច្បាប់ និងបទបញ្ញាអំពីការក្លាយទៅជាពលរដ្ឋរស់នៅជាអចិន្ត្រៃយ៍ មានភាពស្មុគស្មាញ។ ដោយហេតុនេះ គឺជាការសំខាន់ដែលត្រូវទទួលឱវាទផ្នែកច្បាប់ ពីភ្នាក់ងារអន្តោប្រវេសន៍ដែលមានគុណសម្បត្តិ។

### ការសម្ងាត់

ការសម្ងាត់មានន័យថា ពត៌មានណាមួយដែលកិច្ចបំរើផ្នែកសុខភាពមានអំពីលោកអ្នក គឺជាពត៌មានផ្ទាល់ខ្លួន ហើយគេមិនអាចផ្តល់ពត៌មាននោះទៅឲ្យមនុស្សដទៃទៀត ដោយគ្មានការអនុញ្ញាតពីលោកអ្នកឡើយ។ នៅក្នុងប្រទេសអូស្ត្រាលី នេះគឺជាការខុសច្បាប់ដែលភ្នាក់ងារមើលថែសុខភាពណាម្នាក់ ពិភាក្សាអំពីពត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក ជាមួយអ្នកដទៃទៀត។

### ការប្រើប្រាស់អ្នកបកប្រែភាសា

លោកអ្នកអាចប្រើប្រាស់អ្នកបកប្រែភាសា ពេលណាលោកអ្នកកំពុងនិយាយជាមួយភ្នាក់ងារមើលថែសុខភាព ឬកិច្ចបំរើដទៃទៀត។ ក៏ដូចជាភ្នាក់ងារមើលថែសុខភាពទាំងអស់ដែរ អ្នកបកប្រែ**ត្រូវ**ការពាររឿងសម្ងាត់ផ្ទាល់ខ្លួនរបស់លោកអ្នក។

ដោយសារការប្រើប្រាស់អ្នកបកប្រែភាសា លោកអ្នកអាច:

- យល់គ្រប់ទាំងកិច្ចការដែលគេបាននិយាយប្រាប់លោកអ្នក
- ប្រាកដច្បាស់ថាគ្រប់ទាំងកិច្ចការដែលលោកអ្នកនិយាយ នឹងត្រូវបានគេយល់
- សួរសំនួរ ហើយទទួលបានចម្លើយ
- អាចយល់ដឹង ហើយយល់ព្រមធ្វើតេស្ត ឬទទួលការព្យាបាល។

អ្នកបកប្រែភាសាតាមទូរស័ព្ទ (TIS) ក៏មានផ្តល់នៅគ្រប់ទីកន្លែងក្នុងប្រទេសអូស្ត្រាលីដែរ។ សូមទូរស័ព្ទលេខ 131 450 (ដោយបង់ថ្លៃដូចនៅក្នុងតំបន់) ហើយលោកអ្នកនឹងត្រូវគេតភ្ជាប់ទៅកិច្ចបំរើដែលលោកអ្នកចង់និយាយជាមួយ និងអ្នកបកប្រែភាសាតាមទូរស័ព្ទ។

## កិច្ចបំរើទាំងឡាយដែលអាចជួយ:

**មន្ទីរពិនិត្យសួត**

ចំពោះមន្ទីរពិនិត្យសួតដែលនៅជិតលោកអ្នកជាងគេ សូមបើកមើលវិបសាយ:
www.health.nsw.gov.au/publichealth/infectious/tb/pdf/chest_clinics/pdf

**មន្ទីរពិនត្យសុខភាពផ្នែកផ្លូវភេទ**

ចំពោះមន្ទីរពិនិត្យសុខភាពផ្នែកផ្លូវភេទដែលនៅជិតលោកអ្នកជាងគេ សូមរកមើលក្រោមតួអក្សរ ‘S’ ក្នុងសៀវភៅលេខទូរស័ព្ទទំព័រស ឬទូរស័ព្ទទៅបណ្តាញផ្តល់ពត៌មានផ្នែកសុខភាពផ្លូវភេទលេខ 1800 451 624។

**ចំពោះពត៌មានលំអិតបន្ថែមអំពី HIV ជាភាសារបស់លោកអ្នក សូមបើកមើលវិបសាយ:**

កិច្ចបំរើផ្នែករោគ HIV/AIDS និងជម្ងឺរលាកថ្លើមជំពូក C ពហុវប្បធម៌
Multicultural HIV/AIDS and Hepatitis C Service www.multiculturalhivhepc.net.au

**ចំពោះពត៌មានលំអិតបន្ថែមអំពីរោគ TB ជាភាសារបស់លោកអ្នក សូមបើកមើលវិបសាយ:**
កិច្ចបំរើផ្នែកទំនាក់ទំនងសុខភាពពហុវប្បធម៌
Multicultural Health Communication Service www.mhcs.nsw.gov.au

**ក្រសួងសុខាភិបាលរដ្ឋញូវសៅវែល**
www.health.nsw.gov.au/PublicHealth/Infectious/TB/index.asp